# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សាលក្រមព្រហ្មទណ្ឌ

លេខ: ៣១ "ខ"

ចុះថ្ងៃទី០៤ ខែ ឧសភា ឆ្នាំ ២០២២

*.សំណុំរឿងព្រហ្មទណ្ឌលេខ ៣២២*

*ចុះថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០២០*

*.សំណុំរឿងស៊ើបសួរលេខ ២៧៧*

*ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០*

*.សំណុំរឿងជំនុំជម្រះលេខ ៣៥៧*

*ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១*

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង៨ និង ៣០ នាទីព្រឹក នៅសាលាដំបូងខេត្តកំពង់ឆ្នាំង ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

.លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

**តំណាងអយ្យការ**

.លោកស្រី [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជីសវនាការ**

.លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

ដើម្បីជំនុំជម្រះ លើសំណុំរឿងព្រហ្មទណ្ឌលេខ: ៣២២ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] សារ៉ាត ភេទស្រី អាយុ៦៨ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] វែន (រ) ម្តាយឈ្មោះ [redacted] អ៊ុំ (ស) ប្តីឈ្មោះ [redacted] សារិន (រ) មានកូនចំនួន០១នាក់ ទោសពីមុន គ្មាន ជានីតិជន ( ក្រៅឃុំ ) ។

២.ឈ្មោះ [redacted] ម៉ារ៉ា ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted]ត (រ) ម្តាយឈ្មោះ [redacted] ចាន់ (ស) ប្រពន្ធឈ្មោះ [redacted] ស៊ិនថាវី (រ) មានកូនចំនួន០៨នាក់ ទោសពីមុន គ្មាន ជានីតិជន ( ក្រៅឃុំ ) ។

៣.ឈ្មោះ [redacted] ស៊ិនថាវី ភេទស្រី អាយុ៤៦ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូ [redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] សារិន (ស) ម្តាយឈ្មោះ [redacted] សារ៉ាត (រ) ប្តីឈ្មោះ [redacted] ម៉ារ៉ា (រ) មានកូនចំនួន០៨នាក់ ទោសពីមុន គ្មាន ជានីតិជន ( ក្រៅឃុំ ) ។

៤.ឈ្មោះ [redacted] សារុធ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្ប [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] ម៉ារ៉ា (រ) ម្តាយឈ្មោះ [redacted] ស៊ិនថាវី (រ) ទោសពីមុន គ្មាន ជានីតិជន ( ក្រៅឃុំ ) ។



Scanned with CamScanner

៥.ឈ្មោះ [redacted]ន្ទា ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted]ម៉ារ៉ា (រ) ម្ដាយឈ្មោះ [redacted]ស៊ុនថាវី (រ) ទោសពីមុន គ្មាន ជានីតិជន ( ក្រៅឃុំ ) ។

៦.ឈ្មោះ [redacted]ផល្លា ភេទស្រី អាយុ២៣ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត [redacted] ខេត្តកំពង់ឆ្នាំង និងទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted]ម៉ារ៉ា (រ) ម្ដាយឈ្មោះ [redacted] ស៊ុនថាវី (រ) ទោសពីមុន គ្មាន ជានីតិជន ( ក្រៅឃុំ ) ។

ត្រូវជាប់ចោទពីបទៈ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤១១ និងមាត្រា ៥២៣ ចំណុច ២ នៃក្រមព្រហ្មទណ្ឌ ។

.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]រឿន ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

.មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]រឿន ។

.មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឈ្មោះ [redacted] សារ៉ាត, ឈ្មោះ [redacted] ម៉ារ៉ា, ឈ្មោះ [redacted] ស៊ុនថាវី និងឈ្មោះ [redacted] សារ៉ាត ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ ៖**

កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និង ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ មានករណីបទល្មើស ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅចំណុចភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ដែលបង្កឡើងដោយជនជាប់ចោទ ១.ឈ្មោះ [redacted] សារ៉ាត , ២.ឈ្មោះ [redacted] ម៉ារ៉ា , ៣.ឈ្មោះ [redacted] ស៊ុនថាវី, ៤.ឈ្មោះ [redacted] សារុធ ៥.ឈ្មោះ [redacted]ចិន្ទា,៦.ឈ្មោះ [redacted] ផល្លា បានធ្វើសកម្មភាពបុកអណ្ដូងស្នប់ និងបិទផ្លូវមិនឱ្យតុលាការអនុវត្តរោងលាងឡានម៉ូតូ នៅលើដីកម្មសិទ្ធិរបស់ជនរងគ្រោះឈ្មោះ [redacted]រឿន និងប្ដីឈ្មោះ [redacted]ណារី ។

.បានឃើញ ពាក្យបណ្ដឹង ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] រឿន ។

.បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ:៤៧៥/២១ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

.បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៣៧១/២១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។

.បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ៧៤៧/២១ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

.បានឃើញ សាលក្រមលេខ: ១៣៨ "ខ" ចុះថ្ងៃទី០៥ ខែ កក្កដា ឆ្នាំ២០២១ របស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។

.បានឃើញ បណ្ដឹងទាស់ ១.ឈ្មោះ [redacted] សារ៉ាត,២.ឈ្មោះ [redacted]ម៉ារ៉ា,៣.ឈ្មោះ [redacted] ស៊ុនថាវី ៤.ឈ្មោះ [redacted] សារុធ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ បានសុំប្ដឹងទាស់នឹងសាលក្រមលេខ:១៣៨ "ខ" ចុះ



Scanned with CamScanner

ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានបើកសវនាការ ជំនុំជម្រះកំបាំងមុខ សុំឱ្យតុលាការ បើកសវនាការ ជំនុំជម្រះឡើងវិញ ។

**នាពេលសវនាការ**

១.យោងតាមសាលក្រមលេខ: ១៣៨ "ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ ដែលបានបើកសវនាការជំនុំជម្រះ សួរដេញដោលរួចហើយ ដោយកំបាំងមុខជនចាប់ចោទ១.ឈ្មោះ [redacted]សារ៉ាត,២.ឈ្មោះ [redacted]ម៉ារ៉ា,៣.ឈ្មោះ[redacted] ស៊ិនថាវី,៤.ឈ្មោះ [redacted]សារុធ,៥.ឈ្មោះ [redacted]ចន្ថា និង៦.ឈ្មោះ [redacted] ផល្លា នៅក្នុងសំណុំរឿងលេខ:៣២២ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ នេះ ។

នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ ជនជាប់ចោទ១.ឈ្មោះ[redacted]សារ៉ាត,២.ឈ្មោះ [redacted]ម៉ារ៉ា,៣.ឈ្មោះ [redacted] ស៊ិនថាវី,៤.ឈ្មោះ[redacted] សារុធ បានដាក់ពាក្យសុំប្តឹងទាស់និងសាលក្រមលេខ: ១៣៨ "ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ សុំឱ្យតុលាការលើករឿងនេះមកជម្រះឡើងវិញ ដោយហេតុថា ការផ្តន្ទាទោសលើខ្លួនដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗ ០២(ពីរ)ឆ្នាំ ពីបទ: ធ្វើឱ្យខូចខាតដោយចេតនា មានស្ថានទម្ងន់ទោសនិង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ មានការធ្ងន់ធ្ងរពេកនិងពិន័យជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន)រៀល និង បង្គាប់ឱ្យពួកខ្លួនរួមគ្នាសងសំណងជម្ងឺចិត្ត ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] រឿន ចំនួន ៨០.០០០.០០០(សែសិបលាន)រៀល ការសម្រេចសេចក្តីមកលើពួកខ្លួននេះមិនត្រឹមត្រូវនោះទេ អយុត្តិធម៌លើពួកខ្លួន ខ្លួនពុំមានលទ្ធភាពសងទេ ។

២.ជនជាប់ចោទឈ្មោះ[redacted] ម៉ារ៉ា បានឆ្លើយបញ្ជាក់នៅក្នុងអង្គសវនាការថា ឈ្មោះ[redacted]សារ៉ាត គាត់ចាស់ជរា ,ឈ្មោះ [redacted] សារុធ ជាប់មើលកូនឈឺយកទៅពេទ្យភ្នំពេញ, ឈ្មោះ[redacted]ចន្ថា និងឈ្មោះ [redacted]ផល្លា នៅធ្វើការនៅកូរ៉េ ដីកាកោះខ្លួនជាអ្នកទទួលជំនួស ហើយឈ្មោះ ទាំងនេះក៏បានដឹងថា ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ វេលាម៉ោង៨ និង៣០នាទីព្រឹកនេះ តុលាការបានបើកសវនាការជំនុំជម្រះរឿងរបស់ខ្លួនដែរ ។

.ជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ា បានឆ្លើយថា នៅក្នុងរឿងហេតុនេះ ខ្លួនមិនបានធ្វើឱ្យខូចខាតទ្រព្យសម្បត្តិរបស់គេទេ ចំពោះនៅកន្លែងលាងឡាន និងបុកអណ្តូង និងដាំដំណាំផ្សេងៗដែលខ្លួនបានបង្កបង្កើនផលដំណាំនោះ គឺនៅលើដីរបស់ខ្លួន ចំពោះរឿងដីនេះថា មានដីការក្សាការពារ ខ្លួនមិនបានដឹងទេជារឿងរបស់ម្តាយក្មេកខ្លួន ខ្លួនក៏រស់នៅជាមួយគាត់ដែរ ។

ចំពោះដីទំនាស់របស់ម្តាយក្មេកខ្លួនឈ្មោះ [redacted] សារ៉ាត គាត់បានរស់នៅតាំងពីឆ្នាំ១៩៧៩ លុះក្រោយមកមានរឿងរ៉ាវ មានដីកាកោះហៅក្រុមគ្រួសារខ្លួន ដោយមានការពាក់ពាន់ក្នុងរឿងដីនេះ តែរឿងដីនេះពីមុនបានដោះស្រាយជាមួយគ្នាខ្លះដែរ រហូតទៅដល់តុលាការកំពូល ខ្លួនគ្រាន់តែជាអ្នកជូនម្តាយក្មេកទៅភ្នំពេញតែប៉ុណ្ណោះ ហើយរឿងអ្វីៗខ្លួនមិនសូវដឹងទេ នៅលើម្តាយក្មេកឈ្មោះ [redacted] សារ៉ាត ។

ខ្លួនសូមបញ្ជាក់ថា ខ្លួនមិនបានទទួលដីការក្សាការពារអ្វីពីតុលាការទេ ឬ ដីកាសម្រេចណាមួយហាមឃាត់ដីនេះឡើយ ចំពោះដីនេះខ្លួនបានធ្វើកន្លែងលាងឡាន និងបុកអណ្តូង និងដាំដំណាំផ្សេងៗនៅលើដីនេះ ពុំមានអ្នកណាមកហាមឃាត់នោះទេ ។

ខ្លួនសុំឱ្យតុលាការមេត្តាលើកលែងការចោទប្រកាន់ និងសំណងផ្សេងៗ លើក្រុមគ្រួសារខ្លួនផង ព្រោះខ្លួនមិនបានធ្វើអ្វីខុសនោះទេ ។



Scanned with CamScanner

៣.ជនជាប់ចោទឈ្មោះ [redacted] ស៊ិនថាវី បានឆ្លើយថា ឈ្មោះ [redacted] សារ៉ាត ត្រូវជាម្ដាយ បង្កើតខ្លួន ហើយឈ្មោះ [redacted] សាវុធ ជាប់យកកូនឈឺទៅពេទ្យភ្នំពេញ,ឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] ផល្លា នៅធ្វើការ ប្រទេសកូរ៉េ ជាកូនរបស់ខ្លួន ប្ដីខ្លួន និងរូបខ្លួនក៏បានប្រាប់ឱ្យដឹងរួចហើយ ក្នុងការជំនុំជម្រះថ្ងៃនេះ ។

.ជនជាប់ចោទឈ្មោះ [redacted] ស៊ិនថាវី បានឆ្លើយថា ខ្លួនយកតាមចម្លើយប្ដីរបស់ខ្លួន ដែលបានឆ្លើយលើកឡើងពេលសវនាការនេះ ខ្លួនសូមឆ្លើយបញ្ជាក់ជូនតុលាការថា ដីនេះម្ដាយខ្លួនបានរស់នៅតាំងពីឆ្នាំ ១៩៧៩មកម្លេះ ហើយពេលប្ដីខ្លួនធ្វើអាជីវកម្មកន្លែងលាងឡាន និងបុកអណ្ដូង និងដាំដំណាំផ្សេងៗ ពុំមានអាជ្ញាធរណាមកហាមឃាត់នេះទេ ហើយខ្លួនមិនបានធ្វើអ្វីឱ្យខូចខាតនោះទេ ដូចប្ដីខ្លួនបានលើកឡើងជូនតុលាការពេលនេះ ការប្ដឹងចោទប្រកាន់មកលើខ្លួនមិនត្រឹមត្រូវនោះទេ សូមតុលាការជួយរកយុត្តិធម៌ឱ្យក្រុមគ្រួសារខ្លួនផង ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី

ក្រោយពីបានសួរដេញដោយ ជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ា និងឈ្មោះ [redacted] ស៊ិនថាវី ឃើញថា ការឆ្លើយនេះមិនពិតនោះទេ បានឆ្លើយដោះសារ ព្រោះរឿងដីនេះមានសាលដីកាលេខ:៥១៦ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០០៧ របស់តុលាការកំពូលបានសម្រេចអស់ហើយ និងមានដីការក្សាការពារលេខ:០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ហើយម្ចាស់បំណុលឈ្មោះ [redacted] ណាវី ត្រូវជាប្ដីរបស់ឈ្មោះ [redacted] រឿន និងកូនបំណុលឈ្មោះ [redacted] សារ៉ាត និងបានដាក់ពាក្យសុំអនុវត្ត លោកចៅក្រមក៏បានចុះប្រកាសដីការក្សាការពារនេះនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ វេលាម៉ោង៨ព្រឹក និងមានអាជ្ញាធរមូលដ្ឋានភូមិ ឃុំ ស្រុក ចូលរួម ព្រមទាំងម្ចាស់បំណុលឈ្មោះ អ៊ិនណាវី ត្រូវជាប្ដីរបស់ឈ្មោះ [redacted] រឿន និងកូនបំណុលឈ្មោះ [redacted] សារ៉ាត ក៏បានចូលរួមផងដែរ ក្រោយពីបានស្ដាប់ការប្រកាសរបស់ចៅក្រមអនុវត្តរួចមក កូនបំណុលឈ្មោះ [redacted] សារ៉ាត មិនព្រមផ្ដិតមេដៃ រឿងអីថាមិនដឹង ការឆ្លើយដោះសាររបស់ជនជាប់ចោទ សូមតុលាការពិចារណា ម៉្យាងទៀតការធ្វើអាជីវកម្មកន្លែងលាងឡាន និងបុកអណ្ដូង និងដាំដំណាំផ្សេងៗ ឈ្មោះ [redacted] សារ៉ាត,ឈ្មោះ [redacted] ស៊ិនថាវី ,ឈ្មោះ [redacted] ម៉ារ៉ា,ឈ្មោះ [redacted] ចិន្តា,ឈ្មោះ [redacted] សាវុធ និងឈ្មោះ [redacted] ផល្លា បាននាំគ្នាទៅធ្វើសកម្មនៅលើដីដែលកំពុងហាមឃាត់ ហើយដីនេះមានសាលដីកាលេខ:៥១៦ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ របស់តុលាការកំពូលបានសម្រេចអស់ហើយ និងមានដីការក្សាការពារលេខ:០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០១៥ ។

នៅក្នុងរឿងហេតុនេះខ្លួនសុំឱ្យតុលាការតម្កល់សាលក្រមលេខ:១៣៨-ខ-ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ ទុកនៅដដែល ។

## សេចក្ដីសន្និដ្ឋានបួងសុំរបស់តំណាងអយ្យការ

.តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថាក្រោយពីបានសួរដេញដោយជនជាបចោទឈ្មោះ [redacted] ម៉ារ៉ា និងឈ្មោះ [redacted] ស៊ិនថាវី ឃើញថា នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០២០ ពិតជាមានអង្គហេតុ បទល្មើសពីបទ:ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ពិតមែន ។

ដោយហេតុថា មានសាលដីកាលេខ:៥១៦ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ របស់តុលាការកំពូល បានសម្រេចអស់ហើយ និងមានដីការក្សាការពារលេខ:០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ។



Scanned with CamScanner

នៅពេលសវនាការជនជាបចោទឈ្មោះ [redacted] ម៉ាភ៉ា និងឈ្មោះ [redacted] ស៊ុនថាវី បានឆ្លើយប្រកែកថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នេះទេ ខ្លួនធ្វើអាជីវកម្មកន្លែងលាងឡាន និងបុកអណ្តូង និងដាំដំណាំផ្សេងៗ នៅលើដីរបស់ខ្លួននោះ មិនមានអាជ្ញាធរណាមកហាមឃាត់ទេ តាមការពិនិត្យរកសួតាងតំណាងអយ្យការយល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត ,ឈ្មោះ [redacted] ម៉ាភ៉ា ,ឈ្មោះ [redacted] ស៊ុនថាវី,ឈ្មោះ [redacted] សាវុធ,ឈ្មោះ [redacted] ចន្ថា,ឈ្មោះ [redacted] ផល្លា ពិតជាបានប្រព្រឹត្តបទល្មើសពិតមែន ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ: ១៣៨ "ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូង ខេត្តកំពង់ឆ្នាំង បានផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សារ៉ាត ,ឈ្មោះ [redacted] ម៉ាភ៉ា ,ឈ្មោះ [redacted] ស៊ុនថាវី,ឈ្មោះ [redacted] សាវុធ,ឈ្មោះ [redacted] ចន្ថា,ឈ្មោះ [redacted] ផល្លា ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់០២ឆ្នាំ និងពិន័យជាប្រាក់ចំនួន៤.០០០.០០០រៀល ពីបទ:ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០។ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ៤១១ និងមាត្រា ៥២៣ ចំណុច ២ នៃក្រមព្រហ្មទណ្ឌ ។

និងបង្គាប់ឱ្យឈ្មោះ [redacted] សារ៉ាត ,ឈ្មោះ [redacted] ម៉ាភ៉ា ,ឈ្មោះ [redacted] ស៊ុនថាវី, ឈ្មោះ [redacted] សាវុធ ឈ្មោះ [redacted] ចន្ថា,ឈ្មោះ [redacted] ផល្លា សងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រឿន ចំនួន ៤០.០០០.០០០រៀល ។

យល់ឃើញថា ជនជាប់ចោទបានប្តឹងទាស់និងសាលក្រមលេខ:១៣៨"ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ នៅក្នុងរឿងហេតុនេះ តុលាការបានសួរដេញដោលរួចហើយ ។

ដូច្នេះ តំណាងអយ្យការ សុំតម្កល់ការចោទប្រកាន់ ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ: ៤៧៥ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ទុកនៅដដែល ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោក តែ ចំណាន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សារ៉ាត,ឈ្មោះ [redacted] ម៉ាភ៉ា,ឈ្មោះ [redacted] ស៊ុនថាវី និងឈ្មោះ [redacted] សាវុធ សូមធ្វើសេចក្តីសន្និដ្ឋានជូនលោកចៅក្រមថា ៖

ទី១.ការពាក់ព័ន្ធនិងការធ្វើឱ្យខូចខាតដោយចេតនាដូចកូនក្តីខ្លួនបានលើកឡើងពេលសវនាការនេះ ឃើញថា ដីទំនាស់នេះកូនក្តីខ្លួនរស់នៅតាំងពីឆ្នាំ១៩៧៩ មកម្លេះ តែមានការប្តឹងគ្នារហូតដល់តុលាការកំពូលមានសាលដីកាលេខ:៥១៦ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ សាលដីកានេះបានចូលស្ថាពរ ម្យ៉ាងវិញទៀតរឿងដីទំនាស់នេះមានដីកាសម្រេចរក្សាការពារលេខ:០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ នៅក្នុងអង្គហេតុនេះ កូនក្តីខ្លួនឈ្មោះ [redacted] ម៉ាភ៉ា,ឈ្មោះ [redacted] ស៊ុនថាវី និងឈ្មោះ [redacted] សាវុធ មិនមានជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿងនេះទេ ដូចកូនក្តីខ្លួនបានលើកឡើងហើយ មានតែឈ្មោះ [redacted] សារ៉ាត ជាម្តាយក្មេកដែលទាក់ទងនិងសាលដីកាលេខ:៥១៦ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ និងដីកាសម្រេចរក្សាការពារលេខ: ០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ។

ទី២.កូនក្តីខ្លួនឈ្មោះ [redacted] ម៉ាភ៉ា,ឈ្មោះ [redacted] ស៊ុនថាវី និងឈ្មោះ [redacted] សាវុធ បានធ្វើកន្លែងលាងម៉ូតូ បុកអណ្តូង និងដាំដំណាំផ្សេងៗ នៅលើដីនេះ ក៏មិនមានរដ្ឋអំណាចណា មកហាមឃាត់នោះទេ [redacted] ជាយកសាលដីកាលេខ:៥១៦ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ និងដីកាសម្រេចរក្សាការពារលេខ:០៧ ចុះថ្ងៃទី



Scanned with CamScanner

២៩ ខែមិថុនា ឆ្នាំ២០១៥ មកធ្វើការដាក់បន្ទុកលើកូនក្តីខ្លួនឈ្មោះ [redacted] ម៉ាព៉,ឈ្មោះ [redacted] ស៊ិនថាវី និង ឈ្មោះ [redacted] សាវុធ ទៅវិញ ថាបានប្រព្រឹត្តបទល្មើស ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ។

កូនក្តីខ្លួនបានធ្វើកន្លែងលាងម៉ូតូ បុកអណ្តូង និងដាំដំណាំផ្សេងៗ ជាចំណែកដីរបស់កូនក្តីខ្លួនទេ ពុំមានជាប់ពាក់ព័ន្ធអ្វីក្នុងដីការក្សាការពារនេះទេ ។

ទី៣.ទាក់ទងនិងសំណុំរឿងព្រហ្មទណ្ឌលេខ: ៣២២ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២០ និងមានសាលក្រមលេខ:១៣៨ "ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង បានផ្តន្ទាទោសលើកូនក្តីខ្លួនឈ្មោះ [redacted] សារ៉ាត ,ឈ្មោះ [redacted] ម៉ាព៉ ,ឈ្មោះ [redacted] ស៊ិនថាវី,ឈ្មោះ [redacted] សាវុធ,ឈ្មោះ [redacted] ចន្ថា, ឈ្មោះ [redacted] ផល្លា ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់០២ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ រៀល និងបង្គាប់ឱ្យសងសំណងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រឿន ចំនួន៤០.០០០.០០០ រៀល ។ ពីបទ:ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១១ និងមាត្រា ៥២៣ ចំណុច ២ នៃក្រមព្រហ្មទណ្ឌ ។

ទី៤.ទាក់ទងនិងសាលក្រមលេខ: ១៣៨"ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ កូនក្តីខ្លួនឈ្មោះ [redacted] សារ៉ាត ,ឈ្មោះ [redacted] ម៉ាព៉ ,ឈ្មោះ [redacted] ស៊ិនថាវី,ឈ្មោះ [redacted] សាវុធ បានប្តឹងទាស់សុំឱ្យតុលាការជំនុំជម្រះឡើងវិញ នៅក្នុងអង្គហេតុនេះកូនក្តីខ្លួនឈ្មោះ [redacted] ម៉ាព៉ ,ឈ្មោះ [redacted] ស៊ិនថាវី,ឈ្មោះ [redacted] សាវុធ បានជាប់ចោទពីបទធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ។

សរុបសេចក្តីមក ដើមបណ្តឹងបានប្តឹង និងចោទប្រកាន់មកលើកូនក្តីខ្លួន ដែលទាក់ទងទៅលើសាលក្រមលេខ:១៣៨"ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ បានសម្រេចសេចក្តី ទាក់ទងនិងបទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១១ និងមាត្រា ៥២៣ ចំណុច ២ នៃក្រមព្រហ្មទណ្ឌ ។

សុំឱ្យតុលាការពិចារណាទៅលើអង្គហេតុ និងសុំឱ្យតុលាការកែប្រែសាលក្រមលេខ:១៣៨"ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ ឱ្យកូក្តីខ្លួនឈ្មោះ [redacted] ម៉ាព៉ ,ឈ្មោះ [redacted] ស៊ិនថាវី,ឈ្មោះ [redacted] សាវុធ ដែលមិនមានជាប់ពាក់ព័ន្ធក្នុងសាលដីការបស់តុលាការកំពូល និងដីកាសម្រេចរក្សាការពារនោះទេ សុំឱ្យរួចផុតពីបទចោទ ។

ដោយឡែកឈ្មោះ [redacted] សារ៉ាត ទោះបីជាគាត់មានកំហុសក៏ដោយ មិនបានប្តឹងតវ៉ា ឬទាមទារតទៅទៀតដែរ ការផ្តន្ទាទោសសុំឱ្យព្យួរ និងសំណងរដ្ឋប្បវេណីសុំឱ្យទាបបំផុត ដោយសារគាត់ជាមនុស្សចាស់ជរា រកស៊ីអ្វីមិនកើតនោះទេ សុំឱ្យតុលាការពិចារណា ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [illegible] សារ៉ាត ,ឈ្មោះ [redacted] ន ម៉ាព៉,ឈ្មោះ [redacted] ស៊ិនថាវី និងឈ្មោះ [redacted] សាវុធ បានធ្វើសេចក្តីសន្និដ្ឋានថា សូមឯកភាពតាមការធ្វើសេចក្តីសន្និដ្ឋានរបស់លោកតែ ចំណាន ។

**សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ**

.ជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ា បានសំណូមពរថា: សុំឱ្យតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង និងសុំឱ្យតុលាការមេត្តាលើកលែងទោស និងសំណងរដ្ឋប្បវេណី ។

.ជនជាប់ចោទឈ្មោះ [redacted]ស៊ុនថាវី បានសំណូមពរថា: សុំឱ្យតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យខ្លួនផង និងសុំឱ្យតុលាការមេត្តាលើកលែងទោសដល់ក្រុមគ្រួសារខ្លួនផង និងសំណងរដ្ឋប្បវេណី ។

.ក្រោយពីបាន ស្តាប់ចម្លើយជនជាប់ចោទ

.ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

.ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការប្តឹងសុំ

.ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

.ក្រោយពីបានស្តាប់ សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

.ក្រោយពីបាន ពិនិត្យលើឯកសារភស្តុតាងនានាក្នុងសំណុំរឿង

.ក្រោយពីបាន ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ពិតជាមានអង្គហេតុបទល្មើសពីបទ:ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅចំណុចភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted]សារ៉ាត, ឈ្មោះ [redacted] ម៉ារ៉ា ឈ្មោះ [redacted] ស៊ុនថាវី ឈ្មោះ [redacted] សារុធ , ឈ្មោះ [redacted] ចិន្តា, ឈ្មោះ [redacted] ផល្លា បានបិតផ្លូវមិនឱ្យតុលាការអនុវត្ត និង អាជ្ញាធរមូលដ្ឋាន ចូលទៅទីតាំងអនុវត្ត ដើម្បីអនុវត្តតាមដីកាសម្រេចរក្សាការពារបានឡើយដោយធ្វើរបង និងវាយសំណាញ់ដែក បិតផ្លូវមិនឱ្យតុលាការអនុវត្ត និងធ្វើឱ្យខូចខាតដោយចេតនា ទៅលើជនរងគ្រោះឈ្មោះ [redacted]រឿន ថែមទៀត ។

២.អង្គហេតុបទល្មើសពីបទ: ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅចំណុចភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ដែលកើតមានឡើងនៅទីកន្លែង និងពេលវេលា ដូចខាងលើ ពិតជាបានប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] សារ៉ាត, ឈ្មោះ [redacted] ម៉ារ៉ា, ឈ្មោះ [redacted] ស៊ុនថាវី, ឈ្មោះ [redacted] សារុធ, ឈ្មោះ [redacted]ចិន្តា, ឈ្មោះ [redacted] ផល្លា បានធ្វើរបង និងវាយសំណាញ់ដែក បិតផ្លូវមិនឱ្យតុលាការអនុវត្ត និងអាជ្ញាធរមូលដ្ឋាន ចូលទៅទីតាំងអនុវត្ត ( រោងលាងឡានម៉ូតូ ) ដើម្បីអនុវត្តតាមដីកាសម្រេចរក្សាការពារបានឡើយ ។

៣.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាត, ឈ្មោះ [redacted]ម៉ារ៉ា, ឈ្មោះ [redacted] ស៊ុនថាវី ឈ្មោះ [redacted]សារុធ, ឈ្មោះ [redacted]ចិន្តា, ឈ្មោះ [redacted]ផល្លា បានធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងមិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅចំណុចភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ទៅលើជនរងគ្រោះឈ្មោះ [redacted] រឿន ។

៤.មានភស្តុតាងសាលដីកាលេខ:៥១៦ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ របស់តុលាការកំពូល ដីកាសម្រេចរក្សាការពារលេខ:០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងកំណត់ហេតុស្តីពីការចុះអនុវត្ត ចុះថ្ងៃទី



Scanned with CamScanner

០៤ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមនៃសាលាដំបូងខេត្តកំពង់ឆ្នាំង។ តែជនជាប់ចោទឈ្មោះ ប៉ែន សារ៉ាត ,ឈ្មោះ [redacted] ម៉ារ៉ា, ឈ្មោះ [redacted]ស៊ិនថាវី, ឈ្មោះ [redacted] សារុធ, ឈ្មោះ [redacted] ចិន្តា, ឈ្មោះ [redacted] ផល្លា មិនគោរពច្បាប់ បានបង្ករបទល្មើសពីបទៈធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងមិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅចំណុចភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ទៅលើជនរងគ្រោះឈ្មោះ [redacted] រឿន ។

៥.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ[redacted] សារ៉ាត , ឈ្មោះ[redacted] ម៉ារ៉ា, ឈ្មោះ[redacted] ស៊ិនថាវី ឈ្មោះ [redacted] សារុធ ,ឈ្មោះ[redacted] ចិន្តា,ឈ្មោះ [redacted] ផល្លា មានភស្តុតាងគ្រប់គ្រាន់ ក្នុងបទល្មើសព្រហ្មទណ្ឌ ដូចដែលដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និង មិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅចំណុចភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១១ និង មាត្រា៥២៣ ចំណុច២ នៃក្រមព្រហ្មទណ្ឌ តាមដីកាសន្និដ្ឋានស្ថាពរលេខៈ៤៧៥ អ.យ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តកំពង់ឆ្នាំង និងដីកាសម្រេចបញ្ជូន សំណុំរឿងទៅជំនុំជម្រះលេខៈ ៣៧១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។

៦.សេចក្តីសន្និដ្ឋានរបស់លោក[redacted]ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រឿន បានសុំ ឱ្យតុលាការតម្កល់សាលក្រមលេខៈ ១៣៨ "ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូង ខេត្តកំពង់ឆ្នាំងទុកជាបានការដដែល គប្បីតុលាការពិចារណាតាមច្បាប់ ។

៧.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ នៅតែរក្សាការចោទប្រកាន់ ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខៈ ៤៧៥ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ដដែល គប្បីតុលាការពិចារណាតាមច្បាប់ ។

៨.សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted] សារ៉ាត , ឈ្មោះ[redacted]ារ៉ា, ឈ្មោះ[redacted]ស៊ិនថាវី ,ឈ្មោះ[redacted] សារុធ បានប្តឹងសុំឱ្យតុលាការលើកលែងទោស និងប្រាក់ពិន័យ និងសំណងរដ្ឋប្បវេណី ដែលនៅក្នុងសាលក្រមលេខៈ ១៣៨ "ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង គប្បីតុលាការពិចារណាទៅតាមច្បាប់ ។

ដោយឡែកឈ្មោះ [redacted] សារ៉ាត ទោះបីជាគាត់មានកំហុសក៏ដោយ មិនបានប្តឹងតវ៉ា ឬទាមទារតទៅទៀតដែរ ការផ្តន្ទាទោសសុំឱ្យព្យួរ និងសំណងរដ្ឋប្បវេណីសុំឱ្យទាបបំផុត ដោយសារគាត់ជាមនុស្សចាស់ជរា រកស៊ីអ្វីមិនកើតនោះទេ សុំឱ្យតុលាការពិចារណា គប្បីតុលាការពិចារណាទៅតាមច្បាប់ ។

៩.អំពើរបស់ជនជាប់ចោទ១.ឈ្មោះ[redacted]សារ៉ាត ភេទស្រី អាយុ៦៨ឆ្នាំ , ២.ឈ្មោះ[redacted] ម៉ារ៉ា ភេទប្រុស អាយុ៤៨ឆ្នាំ ,៣.ឈ្មោះ[redacted]ស៊ិនថាវី ភេទស្រី អាយុ៤៦ឆ្នាំ ,៤.ឈ្មោះ [redacted] សារុធ ភេទប្រុស អាយុ២៧ឆ្នាំ, ៥.ឈ្មោះ[redacted]ចន្ទា ភេទស្រី អាយុ២៥ឆ្នាំ និង ៦.ឈ្មោះ[redacted]ផល្លា ភេទស្រី អាយុ២៧ឆ្នាំ មានចេតនាទុច្ចរិត ប្រព្រឹត្តបទល្មើស ពីបទៈ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងមិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ដែលជាអំពើធ្វើឱ្យប៉ះពាល់ សណ្តាប់ធ្នាប់របៀបរៀបរយ ហើយអំពើនេះត្រូវបានច្បាប់កំណត់ថា ជាបទល្មើសព្រហ្មទណ្ឌ និង ត្រូវផ្តន្ទាទោសតាមច្បាប់ ។



Scanned with CamScanner

១០.មានភស្តុតាងដាក់បន្ទុក និង ពិរុទ្ធភាពគ្រប់គ្រាន់ លើជនជាប់ចោទ១.ឈ្មោះ [redacted] សារ៉ាត ភេទស្រី អាយុ៦៨ឆ្នាំ ,២.ឈ្មោះ [redacted] ម៉ារ៉ា ភេទប្រុស អាយុ៤៨ឆ្នាំ ,៣.ឈ្មោះ [redacted] ស៊ុនថាវី ភេទស្រី អាយុ ៤៦ឆ្នាំ,៤.ឈ្មោះ [redacted] សារុធ ភេទប្រុស អាយុ២៧ឆ្នាំ, ៥.ឈ្មោះ [redacted] ចន្ថា ភេទស្រី អាយុ២៥ឆ្នាំ និង ៦.ឈ្មោះ [redacted] ផល្លា ភេទស្រី អាយុ២៣ឆ្នាំ ជាតិខ្មែរ ពីបទៈ ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស និងមិនគោរពតាមដីកាសម្រេចរក្សាការពាររបស់តុលាការកំពូល ប្រព្រឹត្តនៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ និងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ បទល្មើសដែលចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១១ និងមាត្រា ៥២៣ ចំណុច ២ នៃក្រមព្រហ្មទណ្ឌ ។

១១.យោងតាមមាត្រា ៤១១ ស្ថានទម្ងន់ទោស ៖

បទល្មើសដែលមានចែងក្នុងមាត្រា ៤១០(បទមជ្ឈឹមធ្វើឱ្យខូចខាតដោយចេតនា) នៃក្រមនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំនិងពិន័យជាប្រាក់ពី៤.០០០.០០០ (បួនលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល នៅក្នុងករណីដូចតទៅ ៖

១.កាលបើបទល្មើសនេះ បានប្រព្រឹត្តដោយបុគ្គលច្រើនរូប ធ្វើសកម្មភាពក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។

២.កាលបើបទល្មើសនេះ បានប្រព្រឹត្តនៅក្នុងទីកន្លែងជាលំនៅឋាន ។

៣.កាលបើបទល្មើសនេះបានប្រព្រឹត្តនៅក្នុងទីកន្លែង សម្រាប់តម្កល់មូលនិធិតម្លៃ ទំនិញ ឬសម្ភារៈ ។

៤.កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ដល់សំណង់គ្រឹះស្ថានសាធារណៈ ឬផ្លូវសាធារណៈ ។

៥.កាលបើបទល្មើសនេះ បានប្រព្រឹត្តនាំឱ្យខូចប្រយោជន៍ដល់ដំណាំ ឬកសិផល ។

៦.កាលបើបទល្មើសនេះបានប្រព្រឹត្តនាំឱ្យខូចបង្គោលព្រំដែនអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

១២. យោងតាមមាត្រា ៥២៣ បទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ ៖

.អំពើរិះគន់លិខិតឬសេចក្តីសម្រេចរបស់តុលាការ ក្នុងគោលដៅបង្កឱ្យមានភាពវឹកវរដល់សណ្តាប់ធ្នាប់សាធារណៈ ឬ ក៏បង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)និងពិន័យជាប្រាក់ពី១០០.០០០ (មួយសែន) រៀលទៅ ១.០០០.០០០ (មួយលាន) រៀល ។

.អំពើដែលមិនអនុវត្តសេចក្តីសម្រេចរបស់តុលាការ ត្រូវផ្តន្ទាទោសដូចគ្នានឹងទោសដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើ ។

១៣.ជនជាប់ចោទឈ្មោះ [redacted] ម៉ារ៉ា និង ឈ្មោះ [redacted] ស៊ុនថាវី មានស្មារតីគ្រប់គ្រាន់ ក្នុងការប្រព្រឹត្តអំពើខុសច្បាប់ ហើយជានីតិជន ដែលមានសមត្ថភាពពេញលេញ ក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

## ហេតុដូច្នេះសម្រេច

.តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ១៣៨ "ខ" ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ទុកជាបានការដដែល ។



Scanned with CamScanner

.សាលក្រមនេះជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] ម៉ារ៉ា, ឈ្មោះ [redacted]ស៊ុនថាវី និងលោក តែ ចំណាន និងលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងលោក[redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted]សារ៉ាត, ឈ្មោះ [redacted] សារុធ, ឈ្មោះ [redacted]ចន្ថា និងឈ្មោះ [redacted]ល្លា តែចាត់ទុកចំពោះមុខ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ ។

.ទុកសិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងរយៈពេលដែលច្បាប់កំណត់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ៨កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
កំពង់ឆ្នាំង ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]



Scanned with CamScanner